**ក្រសួងអប់រំ យុវជន និងកីឡា**
**នាយកដ្ឋានគោលនយោបាយ**

អត្ថបទស្រាវជ្រាវប្រតិបត្តិ

## មូលហេតុអ្វីសិស្សមួយចំនួនមិនសូវចេះអានអក្សរនៅវិទ្យាល័យ ហ៊ុន សែន បល្ល័ង្ក ខេត្តកំពង់ធំ

អែម អៀងស៊ន[១] នាគ វ៉ាសុក្រី[២] សុក សុវិជ្ជា[៣] ប៉ាង វ៉ាប៉ូលី[៤] មាស សុគឿន[៥] ទូច ធូ[៦] អ៊ឹម យ៉ុនណារ៉ា[៧] ភ្លូ គឹមសាន[៨] វែត កុល[៩] អ៊ិត គឹមស្រ៊ុន[១០] និង កែ ដារិទ្ធ[១១]

វិទ្យាល័យហ៊ុន សែន បល្ល័ង្ក

បានទទួលៈ ០១ មករា ២០២២ បោះពុម្ពផ្សាយៈ ១៥ មិថុនា ២០២២

## សង្ខិត្តន័យ

ចាប់ពីឆ្នាំ ២០១៨ រហូតដល់ឆ្នាំ ២០២១ ទិន្នន័យនៃការសិក្សាតាមរយៈការចូលអានសៀវភៅនៅក្នុងបណ្ណាល័យត្រូវបានធ្លាក់ចុះជាបន្តបន្ទាប់ពីកម្រិត ៨៣.២៨% មកនៅត្រឹមតែ ៤១.៦៤%។ ផ្អែកតាមការសង្កេតនៅតាមថ្នាក់រៀនបង្ហាញថា សិស្សានុសិស្សភាគច្រើនមិនអាចអានអក្សរតាមអក្ខរាវិរុទ្ធ និងឃ្លាឃ្លោងបានត្រឹមត្រូវនៅឡើយ។ ហេតុនេះ ក្រុមអ្នកស្រាវជ្រាវបានកំណត់យកបញ្ហានេះមកធ្វើជាប្រធានបទ។ ការសិក្សានេះ មានគោលបំណងស្វែងរកមូលហេតុដែលធ្វើឱ្យសិស្សមួយចំនួនមិនសូវចេះអានអក្សរៈ ករណីសិក្សាវិទ្យាល័យ ហ៊ុន សែនបល្ល័ង្ក ខេត្តកំពង់ធំ។

វិធីសាស្ត្រស្រាវជ្រាវនេះ ត្រូវបានប្រើប្រាស់កម្រងសំណួរនិងការសម្ភាសដែលមានអ្នកចូលរួមសរុបចំនួន១៥នាក់ក្នុងនោះ មាននាយកសាលា០១នាក់ លោកគ្រូ អ្នកគ្រូ០២នាក់ អ្នកអាណាព្យាបាល ០២នាក់និងសិស្សានុសិស្ស១០នាក់។ ទិន្នន័យដែលទទួលបានពីការសម្ភាសបានកំណត់ទៅតាមក្រុមនៃថ្នាក់ពាក្យ។ តាមលទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថា មានកត្តាចំនួន ៣ ដែលធ្វើឱ្យសិស្សមិនសូវ

ចូលចិត្តអានអក្សរគឺកត្តាគ្រូបង្រៀន កត្តាគ្រួសារ និងកត្តាសិស្ស។ យោងតាមលទ្ធផលខាងលើនេះ សាលារៀនគួរតែរៀបចំព្រឹត្តិការណ៍ ឬសកម្មភាពដើម្បីជំរុញសិស្សានុសិស្សឱ្យយកចិត្តទុកដាក់និងយល់ពីសារៈសំខាន់នៃការអានសៀវភៅ។ ឪពុកម្ដាយសិស្ស ឬអ្នកអាណាព្យាបាលគួរប្រើពេលវេលាជាមួយកូនៗ និងផ្ដល់ថវិកាទ្រទ្រង់លើការទិញសៀវភៅសិក្សាបន្ថែមសម្រាប់កូនៗរបស់គាត់ ព្រមទាំងរៀបចំកន្លែងអង្គុយរៀននិងបង្កើតបណ្ណាល័យតាមផ្ទះឱ្យបានសមរម្យ។

ជារួម កត្តាដែលធ្វើឱ្យសិស្សមិនសូវចេះអានអក្សរមាន កត្តាគ្រូបង្រៀន កត្តាគ្រួសារ និងកត្តាសិស្ស។ ដូច្នេះអ្នកពាក់ព័ន្ធទាំងអស់ត្រូវយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហាខាងលើនេះដើម្បីទាក់ទាញនិងលើកទឹកចិត្តសិស្សឱ្យមកចាប់អារម្មណ៍ទៅលើការអានសៀវភៅវិញ។

**អាគតដ្ឋាន:** អែម, អ., នាគ, វ., &សុក, ស.,(២០២២). មូលហេតុអ្វីសិស្សមួយចំនួនមិនសូវចេះអានអក្សរនៅវិទ្យាល័យ ហ៊ុន សែន បល្ល័ង្គ ខេត្តកំពង់ធំ . *កាលិកបត្រអប់រំកម្ពុជា,* ៥(១),២០-២៨។

## ១.សេចក្តីផ្តើម

នៅក្នុងប្រទេសកម្ពុជាមិនថា តំបន់ណា ឬសាលារៀនណាឡើយ សិស្សមិនសូវចូលចិត្តអានសៀវភៅនៅតែជាបញ្ហាដែលត្រូវយកចិត្តទុកដាក់បំផុត។ ការអភិវឌ្ឍប្រទេសជាតិមួយឱ្យរីកចម្រើនគឺត្រូវផ្ដើមចេញពីការអភិវឌ្ឍធនធានមនុស្សជាចម្បង។ ការបណ្ដុះបណ្ដាលមនុស្សឱ្យក្លាយជាពលរដ្ឋល្អទៅបានគឺផ្ដើមចេញពីការអានសៀវភៅដែលជាឃ្លាំងនៃប្រាជ្ញា។ អ្នកប្រាជ្ញជាច្រើនបានចងក្រងនូវឯកសារដើម្បីទុកណែនាំដល់មនុស្សជំនាន់ក្រោយក្នុងការបណ្ដុះសតិបញ្ញា ស្មារតី ឱ្យកាន់តែភ្លឺថ្លាជាពណ្ណរាយចុំថ្មើងជាងមុនជាដរាប។ ការអានច្រើនអាចធ្វើឱ្យមនុស្សទាំងឡាយនៅក្នុងសង្គមមិនថា ចាស់ ឬក្មេងអាចមានឱកាសទទួលបាននូវគំនិតល្អៗជាច្រើន សម្រាប់យកមកធ្វើជាការពិចារណា ហើយទាញយកមកប្រើប្រាស់ជាប្រយោជន៍ដល់ការសិក្សា ក៏ដូចជាការរស់នៅរបស់យើងទាំងអស់គ្នា ដើម្បីចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិឆ្ពោះទៅរកសេចក្ដីចម្រើន។ ដូច្នេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (២០១៥) បានអនុម័តអនុក្រឹត្យរៀបចំទិវាជាតិអំណានដែលប្រព្រឹត្តទៅរៀងរាល់ខែមីនាដើម្បីលើកកម្ពស់ទម្លាប់នៃការអាននិងការចូលចិត្តអាន (រដ្ឋាភិបាលកម្ពុជា, ២០១៥)។ កន្លងមកនេះ យោងតាមការផ្សាយលើគេហទំព័រ (សារព័ត៌មានថ្មីៗ, ២០២២) ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំទិវាជាតិអំណានចំនួន៧លើក។ ក្នុងនោះ ទិវាជាតិអំណានឆ្នាំ២០២២ ប្រារព្ធឡើងក្រោមប្រធានបទស្តីពី «អំណានជួយលើកកម្ពស់គុណភាពជីវិតក្នុងសង្គមឌីជីថល» ក្នុងគោលបំណងបណ្ដុះទម្លាប់អាន ជំរុញ

វប្បធម៌អាន លើកកម្ពស់សមត្ថភាពនៃការអាន ស្តូត កំណាព្យ និងការតែងនិពន្ធជាដើម។ ដើម្បីត្រៀមខ្លួនក្នុងការវាយតម្លៃសមត្ថភាពអំណានរបស់សិស្សដែលមានអាយុចាប់ពី១៥ឆ្នាំ នាយកដ្ឋានធានាគុណភាពអប់រំនៃក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំឯកសារជំនួយស្មារតីស្តីពី «សំណួរតេស្តគំរូនៃកម្មវិធីអន្តរជាតិស្តីពី វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សម្រាប់ប្រទេសកំពុងអភិវឌ្ឍ»។

បន្ថែមពីនេះទៀត ដើម្បីរួមចំណែកក្នុងការផ្លាស់ប្តូរទម្លាប់នេះ យុវជនដែលមានចំណូលចិត្តក្នុងការអាននៅប្រទេសកម្ពុជាបាននិពន្ធសៀវភៅដែលមានចំណងជើងថា «អំណានជាអំណាច (លីម, អំណានជាអំណាច, ២០១៩)»។ នៅក្នុងសំណេរបកស្រាយអំពីការអាន លោកលីមបានបង្ហាញអំពីទស្សនៈនៃការជំរុញលើកទឹកចិត្តនិងវិធីសាស្ត្រឬបច្ចេកទេសនៃការអាន ដើម្បីទទួលបានចំណេះដឹង។ ក្នុងនោះដែរ នៅក្នុងទិវាជាតិអំណានលើកទី២ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន បានបោះពុម្ពស្នាដៃជាច្រើន ដែលសមិទ្ធផលទាំងនោះជាការរួមចំណែកក្នុងការលើកកម្ពស់នូវការអាន ការតែងនិពន្ធ ក៏ដូចជាផ្តល់ចំណេះដឹងទូទៅទាំងផ្នែកសេដ្ឋកិច្ច ទស្សនវិជ្ជា និងចិត្តវិទ្យាផងដែរ។ ស្នាដៃចុងក្រោយរបស់លោកបានសរសេរអំពី «ទ្រឹស្តីអភិវឌ្ឍភាសា និងទ្រឹស្តីអភិវឌ្ឍកុមារ» (ណារ៉ុន, ២០២២)។ យោងតាម ដោ នីដា បានប្រែសម្រួលសៀវភៅដែលមានឈ្មោះថា «ពេលព្រឹកដ៏អស្ចារ្យ» បានលើកឡើងថា «ការអានគឺដើម្បីខួរក្បាល ការហាត់ប្រាណគឺដើម្បីរូបកាយ ការសូត្រធម៌ឬបួងសួងគឺដើម្បីដួងវិញ្ញាណ។ យើងនឹងក្លាយដូចជាសៀវភៅដែលយើងអាន។ មួយវិញទៀត មនុស្សដែលចេះអក្សរតែមិនព្រមអាន ពុំមានលក្ខណៈសម្បត្តិត្រង់ណាដែលប្រសើរជាងអ្នកដែលមិនចេះអក្សរឡើយ»។ នៅក្នុងទ្រឹស្តីខាងលើនេះបានបង្ហាញថា ការអានគឺជាវិធីសាស្ត្រលឿនបំផុតដើម្បីផ្លាស់ប្តូរផ្នែកណាមួយនៃជីវិត ឬជាវិធីសាស្ត្រដើម្បីទទួលចំណេះដឹង គំនិត និងយុទ្ធសាស្ត្រដែលអ្នកត្រូវការឈានទៅរកភាពជោគជ័យនៅក្នុងជីវិត (នីដា, 2020)។

ដូច្នេះ សិស្សានុសិស្សទាំងអស់គប្បីប្រឹងប្រែងព្យាយាមជ្រើសរើសយកសៀវភៅល្អៗមកអានដើម្បីបណ្តុះប្រាជ្ញា ការគិត និងការវិភាគដើម្បីក្លាយជាមូលធនមនុស្សដែលមានសក្តានុពលនៅក្នុងសង្គម។ ផ្ទុយទៅវិញ បច្ចុប្បន្ននេះបច្ចេកវិទ្យាកាន់តែទំនើប សម្ភារៈប្រើប្រាស់កាន់តែសម្បូរបែបស្របពេលជាមួយនឹងបរិបទនៃជំងឺកូវីដ-១៩ ដែលជាបញ្ហាសកលផងនោះបានធ្វើឱ្យមនុស្សមួយចំនួនជាពិសេសសិស្សានុសិស្សមិនសូវចេះអានអក្សរទៅវិញ។ ទាំងនេះជាបញ្ហាមួយគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំងដែលទាមទារឱ្យរាជរដ្ឋាភិបាល ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា រួមទាំងលោកគ្រូ អ្នកគ្រូ និងឪពុកម្តាយ ឬអ្នកអាណាព្យាបាលត្រូវយកចិត្តទុកដាក់និងសហការគ្នាយ៉ាងសកម្មក្នុងការងារអប់រំមួយនេះ។

ដោយឡែក ប្រសិនបើយើងក្រឡេកមកមើលសិស្សានុសិស្សមួយចំនួនតូចនៃវិទ្យាល័យ ហ៊ុន សែន បល្ល័ង្កខេត្តកំពង់ធំវិញ ក៏ទទួលរងឥទ្ធិពលនិងជួបប្រទះនូវបញ្ហាខាងលើនេះដែរ។

**តារាង៖** ស្ថិតិសិស្សចូលអានសៀវភៅនៅបណ្ណាល័យ វិទ្យាល័យ ហ៊ុន សែន បល្ល័ង្ក

| ឆ្នាំសិក្សា | សិស្សសរុប | សិស្សស្រី | ភាគរយ | សិស្សសរុបចូលអាន | សិស្សស្រីចូលអាន |
|---|---|---|---|---|---|
| 2018-2019 | 1292 | 702 | 83,28% | 1075 | 584 |
| 2019-2020 | 1334 | 683 | 62,46% | 833 | 426 |
| 2020-2021 | 1344 | 689 | 41,64% | 559 | 286 |

យោងតាមស្ថិតិសិស្សចូលអានសៀវភៅនៅក្នុងបណ្ណាល័យខាងលើបានបង្ហាញឱ្យឃើញថា៖ នៅឆ្នាំសិក្សា២០១៨-២០១៩ មានសិស្សចូលអានសៀវភៅនៅក្នុងបណ្ណាល័យរហូតដល់៨៣.២៨%។ ចំណែកឯឆ្នាំសិក្សា២០១៩-២០២០ មានសិស្សចូលអានសៀវភៅនៅក្នុងបណ្ណាល័យ៦២.៤៦% ហើយនៅឆ្នាំសិក្សា២០២០-២០២១ មានសិស្សចូលអានសៀវភៅនៅក្នុងបណ្ណាល័យ៤១.៦៤%។ យោងតាមទិន្នន័យបង្ហាញថា ភាគរយសិស្សចូលអានសៀវភៅក្នុងបណ្ណាល័យមានការធ្លាក់ចុះជាលំដាប់ ដោយសារជំងឺរាតត្បាតសកលដែលតម្រូវឱ្យរក្សាគម្លាតសង្គម។ ជាមួយគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡាបានប្រកាសផ្អាកដំណើរការសាលារៀននៅទូទាំងប្រទេស ដោយអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលគឺ ៣ កុំ និង៣ ការពារ ដើម្បីកាត់បន្ថយការរីករាលដាលនៃជំងឺកូវីដ-១៩។

ហេតុនេះ ក្រុមអ្នកស្រាវជ្រាវនៅវិទ្យាល័យ ហ៊ុន សែន បល្ល័ង្កបានលើកយកនូវប្រធានបទដែលទាក់ទងនឹងកម្សោយនៃការអានរបស់សិស្សមួយចំនួនមកធ្វើការវិភាគស្រាវជ្រាវរកឱ្យឃើញថា៖«តើមូលហេតុអ្វីបានជាសិស្សមួយចំនួនមិនសូវចេះអានអក្សរ?»

ដើម្បីស្រាយចម្ងល់ដ៏ចាក់ស្រេះខាងលើនេះ ក្រុមអ្នកស្រាវជ្រាវបានចុះសិក្សានិងឈ្វេងយល់យ៉ាងល្អិតល្អន់ដើម្បីស្វែងរកមូលហេតុដែលនាំឱ្យសិស្សមួយចំនួនមិនសូវចេះអានអក្សរ។ ក្នុងនោះ ការសិក្សាកន្លងមកបានរកឃើញពាក់ព័ន្ធនឹងកត្តា៣យ៉ាងគឺ កត្តាគ្រូបង្រៀន កត្តាគ្រួសារ និងកត្តាសិស្ស។

**កត្តាគ្រូបង្រៀន៖** លោកគ្រូ អ្នកគ្រូ ភាគច្រើនមិនសូវមានសកម្មភាពក្នុងដឹកនាំសិស្សចូលអានក្នុងបណ្ណាល័យនិងមណ្ឌលអាន ដែលធ្វើសិស្សខ្សោយនូវសមត្ថភាពក្នុងការអាននិងសរសេរឱ្យបានត្រឹមត្រូវ។ ទាំងនេះ ជាហេតុផលមួយដែលធ្វើឱ្យសិស្សានុសិស្សមួយចំនួនមានភាពខ្វះខាតទាំងផ្នែកទទួលព័ត៌មាន និងបំណិនផ្នែកអាន។

**កត្តាគ្រួសារ៖** ជាទូទៅនៅក្នុងគ្រួសារនីមួយៗមានស្ថានភាពជីវភាពគ្រួសារផ្សេងៗពីគ្នា ដែលក្នុងនោះគ្រួសារមួយចំនួនបានយកចិត្តទុកដាក់ក្នុងការតាមដាន និងជំរុញកូនក្នុងការសិក្សារៀនសូត្រ តែក៏មានគ្រួសារមួយចំនួនមិនសូវបានជំរុញនិងលើកទឹកចិត្តកូនក្នុងការសិក្សារៀនសូត្រ ដោយសារតែគាត់មានការមមាញឹកក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ព្រមទាំងមិនបានរៀបចំបន្ទប់សិក្សានៅផ្ទះ(មានតុ កៅអី ក្តារខៀន ទូរដាក់សៀវភៅជាដើម)។

**កត្តាសិស្សខ្លួនឯង៖** សិស្សនុសិស្សមួយចំនួនមិនសូវចូលចិត្តអានគឺការអានរបស់គាត់មានរយៈពេលខ្លីចន្លោះពី១០-១៥នាទី ព្រមទាំងអនុវត្តមិនទៀងទាត់។ សិស្សមួយចំនួនតូចមិនមានពេលវេលាគ្រប់គ្រាន់ព្រោះត្រូវជួយការងារផ្ទះឬដើរលក់ដូរតាមតំបន់ផ្សេងៗ ចំណែកសិស្សមួយចំនួនទៀតរវល់ធ្វើកិច្ចការសាលាដែលលោកគ្រូ អ្នកគ្រូបានដាក់ឱ្យ។ សិស្សមួយចំនួនតូចមិនសូវចូលចិត្តអានសៀវភៅដោយលើកហេតុផលថាឈឺក្បាលនិងងងុយដេក។ ម៉្យាងទៀត កត្តាសម្ភារៈនិយមក៏ជាបញ្ហាមួយដែលធ្វើឱ្យសិស្សមួយចំនួនចូលចិត្តលេងហ្គេម(Game) និងមើលយូធូប(YouTube) ដែលជាហេតុធ្វើឱ្យបាត់បង់ពេលវេលាអានសៀវភៅ។

## ២.វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវនេះធ្វើឡើងតាមរយៈការសម្ភាសដើម្បីប្រមូលទិន្នន័យ។ ក្រុមអ្នកស្រាវជ្រាវធ្វើការជ្រើសរើសអ្នកពាក់ព័ន្ធក្នុងការសម្ភាសសរុបចំនួន១៥នាក់ ក្នុងនោះមាន នាយក០១នាក់ គ្រូបង្រៀន០២នាក់ ឪពុកម្តាយ ឬអ្នកអាណាព្យាបាលសិស្ស០២នាក់ និងសិស្សានុសិស្ស១០នាក់ ក្នុងនោះមានស្រីចំនួន០៧នាក់។ ទីតាំងនៃការស្រាវជ្រាវនេះធ្វើឡើងនៅក្នុងវិទ្យាល័យ ហ៊ុន សែន បល្ល័ង្ក ដែលស្ថិតនៅក្នុងភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។

អ្នកផ្តល់សម្ភាសបានធ្វើការឆ្លើយតបនឹងសំណួរស្រាវជ្រាវក្នុងនោះមាន៖ នាយកសាលាបានឆ្លើយចំនួន០៧សំណួរ ដែលទាក់ទងទៅនឹងបណ្ណាល័យ សៀវភៅនៅក្នុងបណ្ណាល័យ ទីកន្លែងអាននៅក្នុងសាលារៀន ការខ្ចីសៀវភៅពីបណ្ណាល័យ ទិន្នន័យសិស្សអានសៀវភៅប្រចាំឆ្នាំ ផែនការសម្រាប់សិស្សានុសិស្សចូលអានសៀវភៅនៅបណ្ណាល័យនិងកម្មវិធីប្រឡងអំណាននៅក្នុងសាលារៀន។ កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូមានចំនួន០៤សំណួរដែលទាក់ទងទៅនឹងសកម្មភាពដឹកនាំសិស្សានុសិស្សអានសៀវភៅ ការជំរុញឱ្យសិស្សអានសៀវភៅនៅផ្ទះ វិធីសាស្ត្រក្នុងការលើកទឹកចិត្តសិស្សឱ្យអានសៀវភៅនៅផ្ទះនិងវិធីសាស្ត្រអានបណ្តាក់នៅក្នុងថ្នាក់រៀន។ សម្រាប់ឪពុកម្តាយ ឬអ្នកអាណាព្យាបាលមានចំនួន០៤សំណួរ ដែលទាក់ទងទៅនឹងសកម្មភាពអានសៀវភៅនៅផ្ទះ ការជំរុញនិងការលើកទឹកចិត្ត

ព្រមទាំងការផ្ដល់សៀវភៅសម្រាប់កូនអាននៅផ្ទះ។ សម្រាប់សិស្សានុសិស្សមានចំនួន០៨សំណួរដែលទាក់ទងទៅនឹងទម្លាប់នៃការអានសៀវភៅនៅផ្ទះ ការជួយបង្រៀនបន្ថែមពីឪពុកម្ដាយ ឬអ្នកអាណាព្យាបាល ចំណង់ចំណូលចិត្តក្នុងការអានសៀវភៅ សារៈប្រយោជន៍នៃការអានសៀវភៅ ការប្រកួតប្រជែងគ្នាក្នុងការអាន ការជួយគ្នាពីរបៀបអានសៀវភៅ ការណែនាំឱ្យមិត្តភក្តិអានសៀវភៅ និងមិត្តភក្តិណែនាំក្នុងការអានសៀវភៅ។

ក្រុមអ្នកស្រាវជ្រាវយើងប្រមូលទិន្នន័យបានតាមរយៈការសម្ភាស ដោយប្រើកម្រងសំណួរ ហើយបានធ្វើការកំណត់ច្បាស់នូវចំនួនអ្នកចូលរួមដូចជា លោកនាយក លោកគ្រូ អ្នកគ្រូ ឪពុកម្ដាយ ឬអ្នកអាណាព្យាបាលសិស្ស រួមទាំងសិស្សានុសិស្សផងដែរ ដែលទាក់ទងទៅនឹងប្រធានបទដែលកំពុងធ្វើការស្រាវជ្រាវ។

ទិន្នន័យបានពីការសម្ភាសត្រូវបានកត់ត្រា ដោយបំពេញព័ត៌មានតាមលំដាប់លំដោយនៃអ្នកចូលរួម ដើម្បីពិនិត្យរកគំនិតសំខាន់ៗដែលមានសារៈប្រយោជន៍ដាក់ក្នុងតារាងតាមលេខរៀងនៃអ្នកចូលរួមម្ដងមួយៗរហូតដល់គ្រប់គ្នា រួចធ្វើចំណាត់ថ្នាក់គំនិតសំខាន់ទាំងនោះ បន្ទាប់មកធ្វើការវិភាគរកលទ្ធផលស្រាវជ្រាវ ដោយអនុវត្តតាមគោលការណ៍ក្រមសីលធម៌នៃអ្នកស្រាវជ្រាវ។

## ៣.លទ្ធផល និងការពិភាក្សា

យោងតាមលទ្ធផលនៃការសម្ភាសបានបង្ហាញឱ្យឃើញថា មានមតិជាច្រើនបានឆ្លុះបញ្ចាំងអំពីមូលហេតុច្បាស់លាស់ ដែលជះឥទ្ធិពលដល់ការមិនសូវចូលចិត្តអានអក្សររបស់សិស្សានុសិស្សនៅក្នុងវិទ្យាល័យ ហ៊ុន សែនបល្ល័ង្ក កត្តាទាំងនោះរួមមាន៖

### ៣.១.កត្តាគ្រូបង្រៀន

លោកគ្រូ អ្នកគ្រូមួយចំនួនពុំសូវបានហៅសិស្សានុសិស្សឱ្យអានបានច្រើនគ្នា ជាហេតុដែលធ្វើពួកគេតូចចិត្តនិងមិនសូវចាប់អារម្មណ៍ក្នុងការអានសៀវភៅ។ មួយផ្នែកទៀត ម៉ោងសិស្សចូលបណ្ណាល័យត្រូវបានជំនួសដោយត្រូវឱ្យសិស្សានុសិស្សធ្វើការងារផ្សេងៗក្នុងសាលា។

### ៣.២.កត្តាគ្រួសារ

ជីវភាពគ្រួសារជាកត្តាមួយយ៉ាងសំខាន់ក្នុងការកំណត់ជោគវាសនានៃការសិក្សារបស់សិស្ស។ បើគ្រួសារសិស្សមានជីវភាពខ្វះខាត នោះកូនៗប្រឈមនឹងការខ្វះខាតពេលវេលាសម្រាប់អានសៀវភៅ ដោយសារត្រូវការរកប្រាក់បន្ថែមដើម្បីជួយគ្រួសារដែលជាសម្ពាយមួយដ៏ធ្ងន់សម្រាប់ពួកគេ។ តាមមតិរបស់ឪពុកម្ដាយ ឬអ្នកអាណាព្យាបាលសិស្សបានលើកឡើងថា *«មូលហេតុដែលនាំឱ្យកូនរបស់ខ្ញុំមិនសូវ*

*ចេះអានដោយសារជីវភាពខ្វះខាត ត្រូវបង្ខំចិត្តបោះបង់សៀវភៅដើម្បីយកពេលវេលាជួយឪពុកម្ដាយក្នុងការរកប្រាក់ចំណូលតាមរយៈការលក់ដូរទៅធ្វើការរាល់ពេលទំនេរ(ការងារតាមម៉ោងទំនេរពីការសិក្សា)*»។ ទាំងនេះជាកត្តាមួយដែលធ្វើឱ្យការអានរបស់កូនធ្លាក់ចុះ។ មួយវិញទៀត មាតាបិតាអូសទាញកូនឱ្យធ្វើការងារផ្ទះ ឬមើលប្អូនៗរបស់ពួកគេ និងជួយធ្វើស្រែចំការឪពុកម្ដាយ ពីព្រោះកូនៗពួកគាត់ដល់វ័យដែលមានកម្លាំងពលកម្មដែលអាចជួយជំនួសការងាររបស់គាត់បានទាំងស្រុងផងដែរ។ ជាមួយគ្នានោះពួកគាត់គិតថា កូនរៀនមិនសូវចេះហើយ រាល់ពេលកូនទំនេរគាត់តែងតែប្រាប់កូនឱ្យជួយធ្វើការងារ ឬរៀនអាជីពផ្សេងៗទៀតដូចជា ផាត់មុខ ធ្វើសក់ រៀនសំអាងការជាដើម។ លើសពីនេះទៀត សិស្សានុសិស្សមួយចំនួនតូចគ្មានលទ្ធភាពទិញសៀវភៅដែលខ្លួនចូលចិត្តអាន ព្រោះសៀវភៅទាំងនោះមានតម្លៃថ្លៃ ហើយគ្មានលក់នៅក្នុងតំបន់ដែលពួកគេរស់នៅ ឬនៅក្នុងបណ្ណាល័យសាលាឬក៏ទីសាធារណៈ(ទីតាំង)។

ម្យ៉ាងវិញទៀត ភាពមិនចុះសម្រុងគ្នារវាងឪពុកម្ដាយដែលអាចឈានទៅដល់ការបែកបាក់គ្នាជាកត្តាជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់កូនៗ ជាពិសេស សម្ពាធផ្លូវចិត្ត។ នៅពេលឪពុកម្ដាយសិស្សបែកបាក់គ្រួសារធ្វើឱ្យសេដ្ឋកិច្ចគ្រួសារមានការធ្លាក់ចុះដែលប៉ះពាល់ដល់អារម្មណ៍របស់កូនៗក្នុងការរៀនសូត្រពិសេសលើការអានសៀវភៅ។ ឪពុកម្ដាយមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់តាមដានការរៀនសូត្ររបស់កូនៗ មិនបានជំរុញកូនឱ្យអាន ឬមើលមេរៀនជាប្រចាំនិងធ្វើកិច្ចការសាលាដែលលោកគ្រូ អ្នកគ្រូបានដាក់ឱ្យ។ ឪពុកម្ដាយមិនទាន់យល់ដឹងពីករណីយកិច្ចរបស់ខ្លួនដែលត្រូវជួយជំរុញបន្ថែមទៅលើការអានរបស់កូនៗគាត់ទាំងនៅផ្ទះ សាលារៀន និងពេលទំនេរ។ ទាំងនោះជាហេតុធ្វើឱ្យកុមារមិនបានទទួលការថែទាំដិតដល់ មិនអាចផ្តោតអារម្មណ៍ក្នុងការអាននិងធ្វើឱ្យការសិក្សាថយចុះ។

### ៣.៣ កត្តាសិស្សខ្លួនឯង

វិទ្យាសាស្ត្រកាន់តែទំនើប សិស្សានុសិស្សភាគច្រើនហាក់មានការរវល់និងចំណាយពេលច្រើនទៅលើការប្រើប្រាស់បច្ចេកវិទ្យា។ រាល់ពេលទំនេរពីការសិក្សា សិស្សានុសិស្សចំណាយពេលលេងទូរស័ព្ទដូចជា លេងហ្គេម(Game)និងមើលបណ្ដាញសង្គមផ្សេងៗទៀត។ គាត់មិនសូវផ្តោតទៅលើការអានសៀវភៅ ទស្សនាវដ្ដី កាសែត ព័ត៌មានផ្សេងៗ និងការស្រាវជ្រាវរកមេរៀនដែលមាននៅក្នុងទូរស័ព្ទនោះទេ។

ចំណែកសិស្សានុសិស្សមួយចំនួនតូច ពួកគេអានច្រើនមិនកើតគឺបណ្ដាលមកពីមូលហេតុរាល់ពេលអាន ធ្វើឱ្យងងុយគេង ឬគេងលក់ ឈឺក្បាល ព្រិលភ្នែក ឈឺឆ្អឹងខ្នង មានពិការភាព និងជំងឺប្រចាំកាយ។ល។ មួយផ្នែកទៀត បណ្ដាលមកពីខ្វះសៀវភៅដែលគាត់ចូលចិត្តអាន ឬពិបាកស្វែងរកសៀវភៅសម្រាប់អាន។

យោងតាមលទ្ធផលនៃកិច្ចសម្ភាស អ្នកចូលរួមទាំងអស់បានលើកឡើងនូវបញ្ហាស្រដៀងគ្នាទាក់ទងនឹងកង្វះការចូលរួមពីឪពុកម្ដាយ ឬអ្នកអាណាព្យាបាលក្នុងការជួយជំរុញការអានរបស់កូនៗ។

សរុបសេចក្ដីមក ការសិក្សាស្រាវជ្រាវលើប្រធានបទនេះវាមានសារៈសំខាន់ណាស់ដើម្បីជួយដល់ប្អូនៗសិស្សានុសិស្ស ឪពុកម្ដាយ ឬអ្នកអាណាព្យាបាល លោកគ្រូ អ្នកគ្រូ នាយកសាលា ឱ្យពួកគាត់មានការយល់ដឹងពីសារៈសំខាន់នៃការអានសៀវភៅដើម្បីអភិវឌ្ឍសមត្ថភាពខួរក្បាលនៃការសិក្សារបស់កូនៗពួកគាត់ផ្ទាល់ ក៏ដូចជាបានជួយសម្រួលបន្ទុករាជរដ្ឋាភិបាលក្នុងការរួមចំណែកអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើននាពេលអនាគត។

## ៤.ចំណុចខ្លាំង និងចំណុចខ្សោយ

ក្រោយពីបានបញ្ចប់កិច្ចការស្រាវជ្រាវលើប្រធានបទខាងលើនេះរួចមក ក្រុមអ្នកស្រាវជ្រាវអាចធ្វើការសន្និដ្ឋានបាននូវចំណុចខ្លាំង និងចំណុចខ្សោយដូចខាងក្រោម៖

**ក.ចំណុចខ្លាំងយើងឃើញថា៖** ១) ក្រុមការងារចេះសហការគ្នាធ្វើការបានល្អ ២) បានចុះធ្វើការងារទៅតាមគម្រោងផែនការធ្វើការទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធ ដឹងតួនាទី និងគោរពពេលវេលា ៣) អ្នកត្រូវចូលរួមសម្ភាសបានផ្ដល់ចម្លើយដោយភាពស្មោះត្រង់ ៤) បង្ហាញពីគោលបំណងនៃការសម្ភាសច្បាស់លាស់ដល់អ្នកចូលរួមផ្ដល់សម្ភាស ៥) រាល់ចម្លើយរបស់អ្នកចូលរួមផ្ដល់សម្ភាសត្រូវរក្សាទុកជាការសម្ងាត់។

**ខ.ចំណុចខ្សោយមានដូចខាងក្រោម៖** ១) រយៈពេលខ្លីពេកសម្រាប់ប្រមូលទិន្នន័យ និងការបង្កើតកម្រងសំណួរ ២) សមាសភាពអ្នកផ្ដល់បទសម្ភាសមានចំនួនតិច ៣) មានការខ្វែងគំនិតគ្នាបន្តិចបន្តួចពេលធ្វើកម្រងសំណួរ និង ៤) មិនបានកំណត់ពេលវេលាសម្រាប់សម្ភាស។

## ៥. សេចក្ដីសន្និដ្ឋាន

ក្រោយពីការវិភាគលទ្ធផលរួចមក អ្នកស្រាវជ្រាវសន្និដ្ឋានបានថាមានកត្តា៣ធំៗដែលជះឥទ្ធិពលនិងប្រឈមខ្លាំងដែលធ្វើឱ្យសិស្សានុសិស្សមិនសូវចូលចិត្តអានអក្សរគឺកត្តាគ្រូបង្រៀន កត្តាគ្រួសារ និងកត្តាសិស្សផ្ទាល់ខ្លួន។ **កត្តាគ្រូបង្រៀន៖** លោកគ្រូ អ្នកគ្រូមួយចំនួនតូចខ្វះវិធីសាស្ត្រក្នុងការបង្រៀនសិស្ស មិនសូវបានសួរសំនួរសិស្ស ពុំសូវហៅសិស្សអានឱ្យបានញឹកញាប់គ្រប់ៗគ្នាឬប្រាប់ឱ្យសិស្សអានមេរៀននៅពេលទំនេរ ដើម្បីឱ្យស្ទាត់ជំនាញក្នុងការអាននិងសរសេរ ពេលម៉ោងចូលបណ្ណាល័យពួកគាត់ឱ្យសិស្សធ្វើការងារផ្សេងៗនិងព្រងើយកន្តើយឬរើសអើងសិស្ស។ **កត្តាគ្រួសារ៖** ឪពុកម្ដាយ ឬអ្នក

អាណាព្យាបាលពុំសូវបានយកចិត្តទុកដាក់និងតាមដានលើការសិក្សារបស់កូនៗ ប្រើប្រាស់កម្លាំងពលកម្មរបស់កូន ដោយឱ្យជួយលក់ដូរ ធ្វើការងារផ្ទះនិងទៅធ្វើការក្រៅម៉ោងរាល់ពេលទំនេរមិនសូវបានលើកទឹកចិត្តកូនៗក្នុងការរៀនសូត្រ និងមិនយល់ពីកាតព្វកិច្ចរបស់កូន។ **កត្តាសិស្សខ្លួនឯង៖** មានពិការភាព ជំងឺប្រចាំកាយ ខ្សោយការអាននិងការសរសេរពាក្យ កាលពីរៀននៅបឋមសិក្សា។ មួយវិញទៀតសិស្សមួយចំនួនញៀនលេងហ្គេម(Game) និងចូលចិត្តមើលបណ្តាញសង្គមផ្សេងៗដែលមិនមានប្រយោជន៍ដល់ការសិក្សារបស់ខ្លួន។

## អនុសាសន៍

បន្ទាប់ពីកំណត់បាននូវបញ្ហាប្រឈមខ្លាំងបំផុតអាចឱ្យក្រុមអ្នកស្រាវជ្រាវផ្តល់អនុសាសន៍មួយចំនួនដូចជា៖ ១.ឪពុកម្តាយ ឬអ្នកអាណាព្យាបាលមានករណីយកិច្ចនិងកាតព្វកិច្ចបញ្ជូនកូនទៅសាលារៀនឱ្យបានគ្រប់ៗគ្នា ពិសេសជំរុញការរៀនសូត្រនៅផ្ទះតាមរយៈការអាន ការធ្វើកិច្ចការសាលាដែលលោកគ្រូ អ្នកគ្រូបានដាក់ឱ្យ។ ២. សាលារៀនគួររៀបចំធ្វើការប្រកួតប្រជែងលើការអានតាមកម្រិតថ្នាក់ដើម្បីជំរុញអានឱ្យកាន់តែប្រសើរឡើង។ លោកគ្រូ អ្នកគ្រូគួរមានតម្លាភាពក្នុងការបង្រៀនអាចឱ្យសិស្សអានបានគ្រប់ៗគ្នានិងជំរុញលើកទឹកចិត្តឱ្យសិស្សខំប្រឹងរៀន(អាន)។ ៣.សិស្សខ្លួនឯងផ្ទាល់គួរថែទាំសុខភាពឱ្យបានល្អ កាត់បន្ថយប្រើទូរស័ព្ទ ដោយយកពេលវេលាមកអានមេរៀន ធ្វើកិច្ចការសាលាដែលលោកគ្រូ អ្នកគ្រូបានដាក់ឱ្យ និងព្យាយាមពង្រឹងសមត្ថភាពអានរបស់ខ្លួនឱ្យកាន់តែល្អប្រសើរឡើង។

## ឯកសារយោង


ដោ នីដា. (2020). *ពេលព្រឹកដ៏អស្ចារ្យ*. ភ្នំពេញ: edu.នាយកដ្ឋានធានាគុណភាពអប់រំ. (២០២០). *ឯកសារជំនួយស្មារតីស្តីពី "សំណួរតេស្តគំរូនៃកម្មវិធី វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍ*. ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

រដ្ឋាភិបាលកម្ពុជា .(២០១៥) .*អនុក្រិត្យស្តីពី ទិវាជាតិអំណាន*. ភ្នំពេញ .រាជរដ្ឋាភិបាលកម្ពុជា :

សារព័ត៌មានថ្មីៗ២០២២) ., មីនា ០៦ .(*ថ្មីៗ* :យកមកវិញពី ថ្មីៗ .

https://thmeythmey.com/?page=detail&id=113166

ហង់ជួន ណារ៉ុន .(២០២២) .*ទ្រឹស្តីអភិវឌ្ឍភាសា និងទ្រឹស្តីនៃការអភិវឌ្ឍកុមារ*. ភ្នំពេញក្រសួងអប់រំ : .យុវជន និងកីឡា

ឡាំ លីម .(២០១៩) .*អំណានជាអំណាច*. ភ្នំពេញ.